ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សេចក្តីជូនដំណឹង

# ស្តីពី

# អត្ថប្រយោជន៍ដែលទទួលបាន ក្រោយរំលាយកិច្ចសន្យាការងារ

ដើម្បីចៀសវាងការបកស្រាយខុសនឹងខ្លឹមសារច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមជម្រាបជូនសាធារណជន អង្គការវិជ្ជាជីវៈ និងបងប្អូនកម្មករនិយោជិតទាំងអស់ មេត្តាជ្រាបថា យោងតាមច្បាប់ស្តីពីការងារ បងប្អូនកម្មករនិយោជិតត្រូវទទួលបាននូវប្រាក់ឈ្នួល និងប្រាក់បំណាច់ ក្រោយរំលាយកិច្ចសន្យាការងារដូចខាងក្រោម៖

## ១. ករណីកិច្ចសន្យាការងារត្រូវបានរំលាយដោយនិយោជក

១.១ ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈនិយោជក ដោយគ្មានហេតុផលត្រឹមត្រូវ ហើយកម្មករនិយោជិតមិនបានប្រព្រឹត្តកំហុសធ្ងន់ ដូចមានចែងក្នុងមាត្រា៨៣ នៃច្បាប់ស្តីពីការងារ និងកំហុសធ្ងន់ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស

ក. ចំពោះកិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC) កម្មករនិយោជិតទទួលបាន៖

- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥% នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យាការងារ (មាត្រា៧៣)
- ជំងឺចិត្តដែលមានចំនួនយ៉ាងតិចស្មើនឹងប្រាក់ឈ្នួល ដែលកម្មករនិយោជិតត្រូវទទួលរហូតដល់ពេលចប់កិច្ចសន្យាការងារ (មាត្រា៧៣) ។

ខ. ចំពោះកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) កម្មករនិយោជិតទទួលបាន៖

- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)
- ប្រាក់បំណាច់ជួសការជូនដំណឹងមុន ក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (មាត្រា៧៥ និងមាត្រា៧៧)
- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយ ដែលកម្មករនិយោជិតត្រូវបានបញ្ឈប់និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសរុប ដែលនិយោជកមិនទាន់បានបើកជូន (មាត្រា៨៩ថ្មី)



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣) ៨៨ ២៧ ៦៩

- ចំពោះសោហ៊ុយជំងឺចិត្ត កម្មករនិយោជិតអាចទាមទារប្រាក់បំណាច់ផ្តាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់អតីតភាពការងារដែលបាន និងទទួលក្នុងកំឡុងពេលនៃកិច្ចសន្យាការងារ (មាត្រា ៩១ថ្មី)។

១.២ ការរំលាយកិច្ចសន្យាការងារដោយឆន្ទៈនិយោជក ដោយកម្មករនិយោជិតបានប្រព្រឹត្តកំហុសធ្ងន់ដូចមានចែងក្នុងមាត្រា៨៣ នៃច្បាប់ស្តីពីការងារ និងកំហុសធ្ងន់ដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស

ក. ចំពោះកិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC) កម្មករនិយោជិតទទួលបាន៖
- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)។

ខ. ចំពោះកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) កម្មករនិយោជិតទទួលបាន៖
- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)។

## ២. ករណីសហគ្រាសក្ស័យធន

ក. ចំពោះកិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC) កម្មករនិយោជិតទទួលបាន៖
- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)
- ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារយ៉ាងតិច ៥% នៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកក្នុងរយៈពេលនៃកិច្ចសន្យាការងារ (មាត្រា៧៣)។

ខ. ចំពោះកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) កម្មករនិយោជិតទទួលបាន៖
- ប្រាក់ឈ្នួលដែលមិនទាន់បានបើក (មាត្រា១១៦)
- ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់ (មាត្រា១៦៦ និងមាត្រា១៦៧)
- ប្រាក់បំណាច់ជួសការជូនដំណឹងមុនក្នុងករណីដែលនិយោជកមិនបានជូនដំណឹងមុនត្រឹមត្រូវតាមច្បាប់ស្តីពីការងារ (មាត្រា៧៥ និងមាត្រា៧៧)
- ប្រាក់បំណាច់អតីតភាពការងារក្នុងឆមាសណាមួយ ដែលកម្មករនិយោជិតត្រូវបានបញ្ឈប់និងប្រាក់រំលឹកប្រាក់បំណាច់អតីតភាពការងារសរុប ដែលនិយោជកមិនទាន់បានបើកជូន (មាត្រា៨៩ថ្មី)។

សម្គាល់៖ ករណីក្ស័យធន មិនមានសោហ៊ុយជំងឺចិត្ត ពីព្រោះកម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារដោយករណីក្ស័យធននេះ មិនរងផលប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ ឬការយល់ច្រឡំរបស់មហាជន ឬកម្មករនិយោជិតដទៃទៀតមកលើខ្លួន ថាគ្មានសមត្ថភាព ឬគ្មានផលិតភាពក្នុងការងារនោះឡើយ។ ការបាត់បង់ការងារទាំងអស់គ្នា គឺមិនមានធាតុផ្សំ ដែលនាំឱ្យមានសំណងជាសោហ៊ុយជំងឺចិត្តនោះទេ។ ករណីការបញ្ឈប់កម្មករនិយោជិត ដោយឡែក ដោយដុំ របស់និយោជក គឺមានធាតុផ្សំ ដែលប៉ះពាល់ដល់កិត្តិយស សេចក្តីថ្លៃថ្នូរ

ស្ល

និងការសង្ស័យពីសហការីជាកម្មករនិយោជិតដទៃលើសមត្ថភាព ឬផលិតភាព ឬឥរិយាបថរបស់កម្មករនិយោជិតដែលត្រូវបញ្ឈប់។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា គ្រប់ភាគីពាក់ព័ន្ធនឹងកាន់តែយល់ច្បាស់អំពីច្បាប់ និងចូលរួមដោះស្រាយអត្ថប្រយោជន៍ជូនបងប្អូនកម្មករនិយោជិតប្រកបដោយស្មារតីទទួលខុសត្រូវ ដើម្បីរក្សាឱ្យបានជាអតិបរមានូវផលប្រយោជន៍ជូនបងប្អូនកម្មករនិយោជិត និងរក្សាបាននូវភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ ព្រមទាំងរក្សាបាននូវភាពប្រកួតប្រជែងរបស់ប្រទេសកម្ពុជាយើងក្នុងការទាក់ទាញវិនិយោគថ្មីៗ និងបង្កើតការងារថ្មីជូនប្រជាជនយើង។

ថ្ងៃព្រហស្បតិ៍ ១២កើត ខែផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមីនា ឆ្នាំ២០២៤